# ម្ចាស់សំឡេង

## ការសិក្សាស្វែងយល់ពីសិទ្ធិស្ត្រីជនជាតិភាគតិច និងជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា

## ១ អ្វីដែលអ្នកគួរដឹង...

នៅប្រទេសកម្ពុជា ស្ត្រីនិងក្មេងស្រីនៅតែបន្តជួបប្រទះ ការរើសអើងនិងអំពីហិង្សា ដែលក្នុងនោះស្ត្រីម្នាក់ នាក់ក្នុងចំណោមស្ត្រី៥ នាក់ (២១%) បានរាយការណ៍ថា ខ្លួនបានជួបប្រទះអំពើហិង្សាលើយេនឌ័រ។ យ៉ាងណាមិញ ចំណុចសំខាន់ដែលត្រូវកត់សម្គាល់នោះគឺ មិនមែនស្ត្រីទាំងអស់នៅក្នុងប្រទេសកម្ពុជាមានបទពិសោធន៍ដូចគ្នាទេ។ បទពិសោធន៍ផ្ទាល់ខ្លួនរបស់ស្ត្រី គឺអាស្រ័យទៅលើកត្តាវប្បធម៌សាសនាសេដ្ឋកិច្ចនិងកត្តាសង្គមផ្សេងទៀត។ស្ត្រីជនជាតិដើមភាគតិចនិងជនជាតិភាគតិចផ្សេងទៀតប្រឈមមុខនឹងទម្រង់ផ្សេងៗនៃការរើសអើង ការផាត់ចេញ និងភាពងាយរងគ្រោះទៅនឹងអំពើហិង្សា។

ទន្ទឹមនឹងបញ្ហាប្រឈមទាក់ទងនឹងយេនឌ័រ និងអត្តសញ្ញាណជាជនជាតិភាគតិច ពួកគេក៏ប្រឈមនឹង 'បន្ទុកផ្ទួនៗ' ផងដែរ។ ការទទួលស្គាល់ឲ្យកាន់តែទូលំទូលាយ និងអន្តរាគមន៍ជាបន្ទាន់ក្នុងការដោះស្រាយបញ្ហាដែលមានភាពប្រទ្បាក់ក្រឡាគ្នាទាំងនេះឲ្យទាន់ពេលវេលាគឺជាការចាំបាច់ ដោយធានាថា ស្ត្រីជនជាតិភាគតិចនិងជនជាតិដើមភាគតិចត្រូវបានយកចិត្តទុកដាក់និងគិតគូរជាចម្បងទៅក្នុងដំណើរការសម្រេចចិត្តទាំងឡាយណាដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។

## ២ តើការស្រាវជ្រាវនេះសិក្សាអំពីអ្វី?

ការស្រាវជ្រាវដែលមានចំណងជើងថា "ម្ចាស់សំឡេង៖ ការសិក្សាស្វែងយល់ពីសិទ្ធិស្ត្រីជនជាតិភាគតិច និងស្ត្រីជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា"នេះ គឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមដែលដឹកនាំដោយអង្គការនារីដើម្បីសន្តិភាព ( ន.ដ.ស )។ការស្រាវជ្រាវនេះ សហការជាមួយស្ត្រីជនជាតិភាគតិចនិងជនជាតិដើមភាគតិចមកពីបួនសហគមន៍ផ្សេងៗគ្នានៅប្រទេសកម្ពុជា ក្នុងនោះរួមមានសហគមន៍ចាម ខ្មែរក្រោម ជនជាតិភាគតិចវៀតណាម និងជនជាតិដើមភាគតិច ដែលមកពីខេត្ត កំពង់ឆ្នាំង កណ្តាល សៀមរាប មណ្ឌលគីរី និងរតនគីរី។ ពួកគេបានសហរៀបចំដំណើរការស្រាវជ្រាវនេះ ដើម្បីបង្ហាញពីបទពិសោធន៍ បញ្ហាប្រឈម តម្រូវការ និងចក្ខុវិស័យរបស់ពួកគេ។ ការសិក្សាស្រាវជ្រាវនេះមានការចូលរួមពីស្ត្រីជនជាតិភាគតិចនិងជនជាតិដើមភាគតិចនៅសហគមន៍ចំនួន ២០៥ នាក់ ដើម្បីចែករំលែកពីរឿងរ៉ាវជីវិត ឧបសគ្គដែលពួកគេជួបប្រទះ និងសំណូមពររបស់ពួកគេ។

ស្ត្រីអ្នកចូលរួមនិងអ្នកស្រាវជ្រាវប្រតិបត្តិក្នុងការសិក្សានេះ តំណាងឱ្យក្រុមភាគតិចដែលងាយរងគ្រោះបំផុតមួយក្នុងប្រទេសកម្ពុជា។ ស្ត្រីនិងក្មេងស្រីទាំងនេះ ទទួលរងនូវផ្នត់គំនិតយេនឌ័រអវិជ្ជមាននៅក្នុងសហគមន៍របស់ពួកគេ ដែលជារឿយៗបំបាក់ទឹកចិត្តពួកគេក្នុងការហ៊ាននិយាយចេញមកក្រៅ ទទួលបានការអប់រំខ្ពស់ ចេញទៅធ្វើការនៅក្រៅផ្ទះ ឬធ្វើជាតំណាងឱ្យសហគមន៍របស់ពួកគេក្នុងមុខតំណែងនយោបាយ ឬការស្វែងរកមតិគាំទ្រ។ លើសពីនេះ ពួកគេក៏ទទួលរងនូវផ្នត់គំនិតអវិជ្ជមានពីសង្គមខ្មែរទូទៅផងដែរដែលធ្វើអោយពួកគេស្ថិតក្នុងភាពងាយរងគ្រោះមួយស្រទាប់ទៀតដោយសារអត្តសញ្ញាណជាតិពន្ធុរបស់ពួកគេ។របាយការណ៍នេះនឹងពិនិត្យមើលបញ្ហាសិទ្ធិស្ត្រីជាច្រើនផ្សេងទៀត ដែលបានចែករំលែកដោយស្ត្រីជនជាតិភាគតិចនិងជនជាតិដើមភាគតិចផ្ទាល់។

# ៣ តើការស្រាវជ្រាវនេះប្រព្រឹត្តទៅដោយរបៀបណា?

ដោយប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមបែបចូលរួមផ្អែកលើគោលការណ៍ហ្វែមមីនីស្ត (FPAR) ការស្រាវជ្រាវនេះ បានបង្កើតឱកាសឱ្យស្ត្រីជនជាតិភាគតិចនិងជនជាតិដើមភាគតិចក្លាយជាសហអ្នកដឹកនាំ និងវិភាគពីរបកគំហើញថ្មីៗអំពីជីវិតនិងការពិតរបស់ពួកគេ។អ្នកស្រាវជ្រាវប្រតិបត្តិដែលជាស្ត្រីវ័យក្មេងមកពីក្រុមភាគតិចទាំងបួនសហគមន៍ត្រូវបានបណ្តុះបណ្តាលចំណេះជំនាញអំពីវិធីសាស្ត្រសាវជ្រាវនេះ ដើម្បីអាចបង្កើតចំណេះដឹង និងបទពិសោធន៍ផ្ទាល់របស់ពួកគេក្នុងការស្វែងយល់ពីបញ្ហាទាំងនេះ និងអាចផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

ការសិក្សាស្រាវជ្រាវដែលប្រើប្រាស់វិធីសាស្ត្រ FPAR នេះ គឺផ្តោតសំខាន់ទៅលើដំណើរការនៃការស្រាវជ្រាវដែលវាមានសារៈសំខាន់ដូចគ្នាទៅនឹងលទ្ធផលនៃការសិក្សានេះ។ ដូចដែលបានរៀបរាប់ក្នុងផ្នែកវិធីសាស្ត្រ (ផ្នែកទី ២) នៃរបាយការណ៍ស្រាវជ្រាវនេះ កាលដែលស្ត្រីមកពីសហគមន៍ងាយរងគ្រោះទាំងនេះបានចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេនិងប្រើប្រាស់សំឡេងរបស់ពួកគេដើម្បីបង្ហាញពីបញ្ហានិងសេចក្តីប្រាថ្នារបស់ពួកគេទៅកាន់សាធារណៈ នោះគឺជាជំហានដ៏សំខាន់មួយ ក្នុងការផ្លាស់ប្តូរអំណាចនៃអ្នកបង្កើតចំណេះដឹង ដែលផ្តោតលើសហគមន៍មូលដ្ឋានជាចម្បង។ ការណ៍នេះអាចនាំឆ្ពោះទៅរករបៀបវារៈនៃការអភិវឌ្ឍន៍មួយប្រកបដោយយុត្តិធម៌និងមានភាពប្រទាក់ក្រឡាគ្នា ទាំងនៅថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ។ របាយការណ៍នេះមានគោលបំណងបង្ហាញពីឧបសគ្គនិងតម្រូវការរបស់ពួកគេតាមរយៈការផ្តល់អាទិភាពដល់ភាពជាម្ចាស់សំឡេងរបស់ពួកគេ។

# ៤ របកគំហើញរបស់យើងមានអ្វីខ្លះ?

## កត្តារាំងក្នុងការទទួលបានការអប់រំ

ស្ត្រីជនជាតិភាគតិចនិងជនជាតិដើមភាគតិចត្រូវបានរើសអើងនៅសាលារៀន ដោយសារតែភាពប្រទាក់ក្រឡាគ្នានៃវិសមភាពយេនឌ័រនិងការរើសអើងជាតិសាសន៍។ បទដ្ឋានវប្បធម៌ដែលផ្តល់អាទិភាពដល់ការអប់ររបស់ក្មេងប្រុស និង ការរើសអើងដោយផ្អែកលើជាតិពិន្ទុ ជាមូលហេតុដែល រារាំងពួកគេមិនអាចទទួលបានការអប់រំ។ ជាក់ស្តែងមាន តែ ២៩% ប៉ុណ្ណោះនៃស្ត្រីអ្នកចូលរួមក្នុងការស្រាវជ្រាវនេះ ដែលបានចែករំលែកថា ខ្លួនមិនធ្លាប់ ត្រូវគេរើសអើងនៅសាលារៀនដោយសារតែអត្តសញ្ញាណជាតិពិន្ទុរបស់ពួកគេ។

## ការដាក់សម្ពាធលើសេរីភាពដើរហើរ

៦៤% នៃអ្នកចូលរួមក្នុងការស្រាវជ្រាវនេះ បានចែករំលែកថាការរឹតត្បិតសេរីភាពដើរហើរបានធ្វើឱ្យពួកគេបាត់បង់ឱកាសអភិវឌ្ឍខ្លួនឯងនិងជំនាញ។ ការរឹតត្បិតសិទ្ធិសេរីភាពនេះ នៅតែបន្តកើតឡើងក្រោមហេតុផលថា ដោយសារក្តីព្រួយបារម្ភអំពីសុវត្ថិភាពរបស់ស្ត្រី ដែលការណ៍នេះបានរារាំងស្ត្រីក្នុងការទទួលបានសិទ្ធិស្វ័យភាព។

## សិទ្ធិទទួលបានឯកសារអត្តសញ្ញាណ

ស្ត្រីខ្មែរក្រោមនិងស្ត្រីជនជាតិភាគតិចវៀតណាមដែលមានគ្រួសារកើតនិងរស់នៅច្រើនជំនាន់នៅកម្ពុជា ជួបបញ្ហាពាក់ព័ន្ធនឹងការទទួលបានឯកសារអត្តសញ្ញាណស្របច្បាប់ដូចជា សំបុត្រកំណើតនិងអត្តសញ្ញាណប័ណ្ណ ដែលរារាំងពួកគេក្នុងការទទួលបានសេវាមូលដ្ឋានសំខាន់ៗ។ ជាក់ស្តែងស្ត្រីខ្មែរក្រោមចំនួន ៩ នាក់ ក្នុងចំណោម ៣១ នាក់ (២៩%)ខ្វះឯកសារអត្តសញ្ញាណ។ ក្នុងចំណោមស្ត្រីជនជាតិភាគតិចវៀតណាម ៤៨ នាក់ដែលចូលរួមក្នុងការស្រាវជ្រាវនេះ មាន ៤១ នាក់ដែលបានកើតនៅប្រទេសកម្ពុជា ដែលក្នុងនោះ មាន ៦៨% មិនមានសំបុត្រកំណើត និង ៦៣% មិនមានអត្តសញ្ញាណប័ណ្ណទេ។ ជាងនេះទៅទៀត សម្រាប់សហគមណ៍ជនជាតិភាគតិចវៀតណាមរស់នៅលើទឹកទាំង ២៣ នាក់ ដែលបានចូលរួមក្នុងការស្រាវជ្រាវនេះ មាន ២២នាក់ បានកើតនិងមានដូនតារស់នៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៦០មកម្ល៉េះ។ ក្នុងចំណោម ២២នាក់នោះ មានតែម្នាក់ប៉ុណ្ណោះដែលមានសំបុត្រកំណើត។

## ឧបសគ្គចំពោះការចូលរួមជាសាធារណៈ

៦១% នៃស្ត្រីអ្នកចូលរួមក្នុងការស្រាវជ្រាវនេះ បានរាយការណ៍ថា មានឧបសគ្គជាច្រើនដែលធ្វើឱ្យពួកគេមិនអាចចូលរួមក្នុងដំណើរការចូលរួមជាសាធារណៈ ដូចជា តួនាទីថែទាំគ្មានកម្រៃ កង្វះការលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋាន និងបញ្ហារសើបផ្នែកសង្គមនិងនយោបាយ។ ការមិនមានឱកាសចូលរួមជាសាធារណៈបែបនេះ ជាបញ្ហាប្រឈមដែលរារាំងភាពជាតំណាងរបស់ពួកគេក្នុងការសម្រេចចិត្តលើបញ្ហានានា។



# តើអ្នកប្រើប្រាស់ការស្រាវជ្រាវនេះដោយរបៀបណា?

ការស្រាវជ្រាវនេះអាចចូលរួមចំណែកយ៉ាងសំខាន់សម្រាប់ការរៀបចំនិងការអនុវត្តគោលនយោបាយជាពិសេសនៅថ្នាក់ជាតិដែលចាំបាច់ត្រូវការយកចិត្តទុកដាក់និងដាក់បញ្ចូលជាចម្បងនូវតម្រូវការនិងសំណូមពររបស់ស្ត្រីជនជាតិភាគតិចនិងជនជាតិដើមភាគតិចក្នុងកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅកាន់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាច។ អ្នកអាចអានពិស្តារលើផ្នែកអនុសាសន៍នៅទំព័រ ២២២ នៃរបាយការណ៍នេះ។

ការប្រកាន់ខ្ជាប់នូវគោលគំនិតភាពប្រទាក់ក្រឡាគ្នានឹងអាចផ្តល់នូវការយល់ដឹងយ៉ាងច្បាស់អំពីរបៀបដែលស្រទាប់នីមួយៗនៃអត្តសញ្ញាណរបស់មនុស្សម្នាក់ៗអាចពាក់ព័ន្ធគ្នា និងអាចកំណត់នូវបទពិសោធន៍ជីវិតរបស់ពួកគេ។ ក្នុងករណីស្ត្រីជនជាតិភាគតិចអត្តសញ្ញាណចម្រុះរបស់ពួកគេដែលជាបន្ទុកផ្ទួនៗផងនោះ ដូចដែលបានរកឃើញក្នុងការស្រាវជ្រាវនេះ ទាមទារឲ្យមានការវាយតម្លៃហ្មត់ចត់ក្នុងក្របខ័ណ្ឌគោលនយោបាយនិងសកម្មភាពជាក់លាក់ក្នុងវិស័យជាច្រើនរួមទាំងការអប់រំឯកសារអត្តសញ្ញាណនិងការចូលរួមសាធារណៈ។

## ការទទួលបានយុត្តិធម៌និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ស្ត្រីជនជាតិភាគតិចនិងជនជាតិដើមភាគតិចដែលរួចផុតពីអំពើហិង្សាទាក់ទងនឹងយេនឌ័រប្រឈមនឹងឧបសគ្គជាច្រើន ក្នុងការទទួលបានយុត្តិធម៌។ កាន់តែពិបាកនោះគឺកង្វះខាតការណែនាំត្រឹមត្រូវ ឬ ការអនុវត្តដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមិនសមរម្យឬមិនមាននីត្យានុកូលភាព។ ការចូលរួមដោះស្រាយវិវាទមូលដ្ឋានតាមប្រពៃណីឬដោយមេដឹកនាំសាសនា ជារឿយៗធ្វើឱ្យស្ត្រីរងគ្រោះប៉ះទង្គិចផ្លូវអារម្មណ៍ម្តងទៀត។

## អំពើហិង្សាទាក់ទងនឹងយេនឌ័រ

ក្នុងចំណោមស្ត្រីជនជាតិដើមភាគតិចដែលបានចូលរួមក្នុងការសិក្សានេះ ៨៤,៦% បង្ហាញថា អំពើហិង្សាក្នុងគ្រួសារនៅតែជាបញ្ហាក្នុងសហគមន៍របស់ពួកគេ។ ការយល់ឃើញទាំងនេះនៅតែមានកម្រិតខ្ពស់ក្នុងចំណោមសហគមន៍ស្ត្រីជនជាតិភាគតិចវៀតណាម (៧៧%) ចាម (៩៣.៧%) និងខ្មែរក្រោម (៨៧.១%)។ អត្តសញ្ញាណជាតិពិន្ទុ កាន់តែធ្វើអោយស្ត្រីជនជាតិភាគតិចងាយរងគ្រោះទៅនឹងការបៀតបៀនផ្លូវភេទ។

## ជម្រកសុវត្ថិភាព និងសេវាជំនួយជាមូលដ្ឋានផ្សេងៗស្តីពីអំពើរហិង្សាទាក់ទងនឹងយេនឌ័រ

ការទទួលបានជម្រកសុវត្ថិភាពសម្រាប់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រនៅមានកម្រិតនៅឡើយ ដែលបង្ខំឱ្យស្ត្រីជាច្រើនស៊ូទ្រាំនឹងការរំលោភបំពានជាបន្តបន្ទាប់ដោយសារតែគ្មានជម្រើស។ ការរៀបចំឱ្យមានជម្រកសុវត្ថិភាព និងការផ្តល់សេវាជាមូលដ្ឋានផ្សេងទៀត ដូចជា សេវាពិគ្រោះយោបល់ផ្លូវច្បាប់ សេវាប្រឹក្សាយោបល់ផ្លូវចិត្ត សេវាពេទ្យ និងសេវាដទៃទៀតឆ្លើយតបនឹងអំពើរហិង្សាទាក់ទងនឹងយេនឌ័រ ប្រកបដោយបរិយាបន្នគឺជាតម្រូវការបន្ទាន់ដែលភាគីពាក់ព័ន្ធគួរយកចិត្តទុកដាក់។

## ការរៀបការវ័យក្មេង

អត្រាខ្ពស់គួរឱ្យព្រួយបារម្ភនៃការរៀបការវ័យក្មេងត្រូវបានរាយការណ៍នៅគ្រប់សហគមន៍ជនជាតិភាគតិចនិងជនជាតិដើមភាគតិចក្នុងការស្រាវជ្រាវនេះ។ ១០០% នៃស្ត្រីជនជាតិដើមភាគតិចដែលចូលរួមក្នុងការស្រាវជ្រាវនេះ បានរាយការណ៍ថា ខ្លួនបានឃើញការរៀបការវ័យក្មេង ក្នុងសហគមន៍របស់ពួកគេ។ ៧២.៩% នៃស្ត្រីជនជាតិភាគតិចវៀតណាម ៧២.៩% នៃស្ត្រីជនជាតិចាម និង ៤៥.២% នៃស្ត្រីខ្មែរក្រោម សុទ្ធតែបានរាយការណ៍អំពីការរៀបការវ័យក្មេង។ កត្តាជំរុញឱ្យមានការរៀបការវ័យក្មេង មានដូចជា បទដ្ឋានវប្បធម៌ និងការអន្តរាគមន៍ដែលគ្មានប្រសិទ្ធភាពសម្រាប់សហគមន៍ ដែលគូសបញ្ជាក់ពីតម្រូវការនៃយុទ្ធសាស្ត្រចាំបាច់ក្នុងការទប់ស្កាត់ការរៀបការវ័យក្មេង។

ក្រសួងពាក់ព័ន្ធនានាគួរអនុវត្តនូវអភិក្រមអន្តរប្រសព្វ ឬ ភាពប្រទាក់ក្រឡាគ្នានេះ នៅក្នុងការតាក់តែងនិងអនុវត្តគោលនយោបាយ ដើម្បីជានានូវគោលការណ៍បរិយាបន្ននិងគ្មាននរណាម្នាក់ត្រូវបានទុកចោល។ នេះមានន័យថា តម្រូវការជាពិសេសរបស់ស្ត្រីជនជាតិភាគតិចនិងជនជាតិដើមភាគតិចត្រូវបានគិតគូរ និង ដាក់បញ្ចូលក្នុងគោលដៅអភិវឌ្ឍន៍ជាតិ និងគោលនយោបាយពាក់ព័ន្ធនានា។ ដៃគូអភិវឌ្ឍន៍ ក៏ដូចជាការិយាល័យអង្គការសហប្រជាជាតិនានាដែលកំពុងធ្វើការនៅក្នុងប្រទេសកម្ពុជា ត្រូវតែផ្តល់អាទិភាពដូចគ្នាចំពោះស្ត្រីនិងក្មេងស្រីជនជាតិភាគតិចនិងជនជាតិដើមភាគតិច ជាពិសេស នៅក្នុងកម្មវិធីយេនឌ័ររបស់ខ្លួន ដែលជារឿយៗក្រុមងាយរងគ្រោះនេះត្រូវបានមើលរំលង។ ជាងនេះទៅទៀតកិច្ចខិតខំប្រឹងប្រែងតស៊ូមតិរបស់សង្គមស៊ីវិលគួរពិចារណាលើការលើកកម្ពស់ការយល់ដឹងដល់សាធារណជនទូទៅអំពីបញ្ហាប្រឈមរបស់ស្ត្រីជនជាតិភាគតិចនិងជនជាតិដើមភាគតិច។ កិច្ចខិតខំប្រឹងប្រែងទាំងនេះមិនមែនដើម្បីលើកកម្ពស់បរិយាបន្នតែប៉ុណ្ណោះទេ វានឹងជួយបន្លើសំឡេងរបស់ពួកគេនៅក្នុងកម្មវិធីទាក់ទឹងនឹងការលើកស្ទួយសិទ្ធិផងដែរ ។

តោះ! រួមគ្នា! យើងអាចបង្កើតលំហមួយដែលមាន សុវត្ថិភាព សមធម៌ និងបរិយាបន្នសម្រាប់ស្ត្រីជនជាតិភាគតិច និងជនជាតិដើមភាគតិច ដើម្បីអនុញ្ញាតអោយពួកគេអាចធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួន និងរស់នៅដោយគ្មានអំពើហិង្សា និងការរើសអើង។

## ៦ តើនរណាជាអ្នកដឹកនាំការស្រាវជ្រាវនេះ?

គំនិតផ្តួចផ្តើមនៃការស្រាវជ្រាវនេះ ត្រូវបានសហដឹកនាំដោយស្ត្រីវ័យក្មេងមកពីសហគមន៍ជនជាតិដើមភាគតិច និងជនជាតិភាគតិចទាំងបួន និងអង្គការនារីដើម្បីសន្តិភាព ដែលមានការឧបត្ថម្ភគាំទ្រពី Women's Fund Asia ( WFA )។



អង្គការនារីដើម្បីសន្តិភាព
Women Peace Makers

Women's Fund Asia